01322268

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 08 / 2016
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E421/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចលើសំណើនានាពាក់ព័ន្ធនឹងពេលវេលាកំណត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង**

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសារណារបស់ភាគីនានាដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ ពាក់ព័ន្ធនឹងការកំណត់យកថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់សំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកភស្តុតាងថ្មីនៅក្នុងសំណុំរឿង ០០២/០២ (*សូមមើល* ឯកសារ E421 កថាខណ្ឌ ៣)។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះ៖

**អនុញ្ញាត** តាមសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យរក្សាទុកពេលវេលាកំណត់ដដែល គឺថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សម្រាប់សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សម្រាប់ឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញា។

**កត់សម្គាល់**ថា ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងពិចារណាលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកភ័ស្តុតាងថ្មី ក្នុងករណីដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យបដិសេធភ័ស្តុតាងថ្មីដែលជនជាប់ចោទបានស្នើសុំឱ្យទទួលយក ហើយត្រូវបានអង្គជំនុំជម្រះទទួលយកនៅក្រោយថ្ងៃទី ០១ ខែ កញ្ញា។

**អនុញ្ញាត** តាមសំណើរបស់មេធាវីការពារក្តី នួន ជា និង ខៀវ សំផន សុំពន្យារពេលរហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដើម្បីឆ្លើយតបទៅនឹងរាល់សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់បន្តបន្ទាប់ក្រោយសំណើសុំ E319/52 និង សំណើសុំផ្សេងទៀត ដែលអាចដាក់នៅមុនថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ឬ ដើម្បីដាក់សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយក្រុមមេធាវីការពារក្តី ដោយសារតែការដាក់បង្ហាញឯកសារពីសហព្រះរាជអាជ្ញានៅក្នុងអំឡុងពេលពេលនោះដែរ។

**ជូនដំណឹង** ដល់ភាគីថា អង្គជំនុំជម្រះត្រូវចាត់ទុកថាជាការដាក់សំណើសុំយឺតពេលអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពីសំណាក់មេធាវីការពារក្តី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ប្រសិនបើសំណើសុំទាំងនោះដាក់នៅក្រោយរយៈពេល ១៤ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការដាក់បង្ហាញឯកសារ។

**ជូនដំណឹង** ដល់ភាគីថា សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលទាក់ទិននឹងអ្នកជំនាញដែលត្រូវអង្គជំនុំជម្រះសម្រេចកោះហៅនោះ នឹងមានការកំណត់ពេលវេលាដាច់ដោយឡែក។

**បដិសេធ** សំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែលតម្រូវឱ្យសហព្រះរាជអាជ្ញាចង្អុលបង្ហាញនូវព័ត៌មានដោះបន្ទុក នៅក្នុងឯកសារដែលសហព្រះរាជអាជ្ញាត្រូវដាក់បង្ហាញ។ និង

**បញ្ជាក់ឡើងវិញ**ថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចបង្ហាញនូវសម្ភារដែលអាចដោះបន្ទុកដែលខ្លួនមាន រហូតដល់បញ្ចប់សំណុំរឿង ០០២/០២។

២. សំអាងហេតុពេញលេញសម្រាប់សេចក្តីសម្រេចនេះនឹងចេញនៅក្នុងពេលសមស្របខាងមុខ។